**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១១៤៨.អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ មាត្រា៣២និងមាត្រា៣៣ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៦ថ្មី នៃអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២២/០០៤ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា២៧ និងមាត្រា៣៤ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រាមួយ .-**

មាត្រា១២ នៃអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកែសម្រួលដូចខាងក្រោម៖

**មាត្រា១២ .- ថ្មី**

នាយកដ្ឋាននីតិកម្មកសិកម្ម មានភារកិច្ចដូចតទៅ៖
- រៀបចំ កសាងផែនការសកម្មភាព និងគម្រោងអភិវឌ្ឍន៍លើសេចក្ដីព្រាងច្បាប់និងសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង
- សិក្សា ស្រាវជ្រាវ រៀបចំ តាក់តែង និងកែសម្រួល សេចក្ដីព្រាងច្បាប់ សេចក្ដីព្រាងវិសោធនកម្មច្បាប់ និងសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់ក្រសួង
- ពិនិត្យនិងផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់និងសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តរបស់អង្គភាពចំណុះក្រសួង និងក្រសួងស្ថាប័នពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ ពិនិត្យវាយតម្លៃផលប៉ះពាល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត
- រៀបចំគោលការណ៍ណែនាំស្ដីពីនីតិវិធីស្ដង់ដាប្រតិបត្តិនៃការធ្វើការត្រួតពិនិត្យលើការអនុវត្តច្បាប់របស់ក្រសួង ព្រមទាំងផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសច្បាប់ដល់អង្គភាពនានាចំណុះក្រសួង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានរបស់ក្រសួង

- អភិវឌ្ឍសមត្ថភាពធនធានមនុស្ស តាមរយៈការរៀបចំបណ្តុះបណ្តាលនិងសិក្ខាសាលា ដើម្បីលើកកម្ពស់គុណវុឌ្ឍិដល់មន្ត្រីនីតិកម្មកសិកម្មនិងមន្ត្រីអនុវត្តច្បាប់របស់ក្រសួង
- ពិនិត្យ តាមដានការអនុវត្តតួនាទីភារកិច្ច និងនីតិវិធីខាងវិន័យលើមន្ត្រីអនុវត្តច្បាប់របស់ក្រសួង
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយសហការជាមួយអង្គភាពជំនាញ
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ ផ្នែកឯកកជន និងដៃគូអភិវឌ្ឍនានា ដើម្បីអភិវឌ្ឍនិងអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង
- រៀបចំផែនការ សកម្មភាព និងគម្រោងផែនការថវិកា ប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងនិងចាត់ចែងលើការងាររដ្ឋបាលបុគ្គលិកនិងសម្ភារបរិក្ខាររបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ។

នាយកដ្ឋាននីតិកម្មកសិកម្មត្រូវដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

នាយកដ្ឋាននីតិកម្មកសិកម្មចំណុះអគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រាពីរ .-**

មាត្រា៣២និងមាត្រា៣៣ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកែសម្រួលដូចខាងក្រោម៖

**មាត្រា៣២ .- ថ្មី**

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ មានភារកិច្ចដូចតទៅ៖

- រៀបចំនិងអនុវត្តគោលនយោបាយ បទដ្ឋានគតិយុត្ត ស្តង់ដា ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងអភិវឌ្ឍន៍ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ
- រៀបចំនិងកំណត់ស្តង់ដាប្រព័ន្ធផលិតកម្មកសិកម្មដែលធានាសុវត្ថិភាពស្បៀង រួមមានការអនុវត្តកសិកម្មល្អនិងកសិកម្មសរីរាង្គ និងតាមដានការអនុវត្ត និងធ្វើវិញ្ញាបនកម្មប្រព័ន្ធផលិតកម្មដែលធានាសុវត្ថិភាពស្បៀង
- គ្រប់គ្រងប្រព័ន្ធការងារក្នុងក្របខ័ណ្ឌនៃការអនុវត្តវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ អនុសញ្ញាអន្តរជាតិស្តីពីការការពាររុក្ខជាតិ កិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោក ស្តង់ដាជាតិ តំបន់ និងអន្តរជាតិស្តីពីវិធានការភូតគាមអនាម័យនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- សិក្សាស្រាវជ្រាវពីវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ ដើម្បីលើកកម្ពស់គុណភាពសុវត្ថិភាពផលិតផលកសិកម្មប្រកបដោយភាតរបរិស្ថាន
- អភិវឌ្ឍសមត្ថភាពធនធានមនុស្ស តាមរយៈការអប់រំ បណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពបច្ចេកទេស និងលើកកម្ពស់គុណវុឌ្ឍិរបស់មន្ត្រីការពាររុក្ខជាតិនិងត្រួតពិនិត្យភូតគាមអនាម័យ
- គ្រប់គ្រងស្ថានភាពសមាសភាពចង្រៃ ដោយអនុវត្តវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យចំពោះរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យដែលធ្វើពាណិជ្ជកម្មនាំចូល នាំចេញ ឬដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា

- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃសេវាកម្មបច្ចេកទេសគ្រប់ប្រភេទក្នុងការអនុវត្តវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ លើគុណភាព ប្រសិទ្ធភាព និងហានិភ័យគ្រោះថ្នាក់នៃផលិតផលការពាររុក្ខជាតិគ្រប់ប្រភេទ
- សិក្សាស្រាវជ្រាវនិងវាយតម្លៃគុណភាពនិងប្រសិទ្ធភាពផលិតផលការពាររុក្ខជាតិ
- ផ្តល់សេវាអន្តរាគមន៍កម្ចាត់សមាសភាពចង្រៃ វិភាគវាយតម្លៃកម្រិតសំណល់អតិបរមានៃថ្នាំកសិកម្ម និងសារជាតុបង្កផលប៉ះពាល់ចំពោះសុខភាពនៅក្នុងកសិផល
- វិភាគហានិភ័យសមាសភាពចង្រៃនិងធ្វើវិញ្ញាបនកម្ម ដោយចេញវិញ្ញាបនបត្រភូតគាមអនាម័យចំពោះរាល់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
- គ្រប់គ្រងព័ត៌មានភូតគាមអនាម័យនិងអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងជាសាធារណៈក្នុងក្របខ័ណ្ឌនៃការអនុវត្តវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ
- សិក្សាលក្ខខណ្ឌតម្រូវភូតគាមអនាម័យ ចរចាបើកទីផ្សារ និងសម្រួលពាណិជ្ជកម្មនៃរុក្ខជាតិផលិតផលរុក្ខជាតិនិងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍជាតិអន្តរជាតិ ក្នុងក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាពសម្រាប់វិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ ដើម្បីលើកកម្ពស់គុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម
- ធ្វើទំនាក់ទំនងនិងធ្វើសហប្រតិបត្តិការអន្តរជាតិ ដោយបំពេញការងារតួនាទីផ្លូវការជាតំណាងព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការការពាររុក្ខជាតិ អនុសញ្ញារ៉ូថឺដាមស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារជាតុគីមីគ្រោះថ្នាក់និងថ្នាំកសិកម្មក្នុងពាណិជ្ជកម្មអន្តរជាតិ កិច្ចព្រមព្រៀង ការអនុវត្តលិខិតតុបករណ៍អន្តរជាតិឬតំបន់ និងការចូលរួមរាល់វេទិកាអន្តរជាតិដែលពាក់ព័ន្ធការការពាររុក្ខជាតិនិងភូតគាមអនាម័យ
- គ្រប់គ្រងនិងធ្វើអធិការកិច្ចលើសកម្មភាពពាក់ព័ន្ធនឹងថ្នាំកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្មនិងការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលអគ្គនាយកប្រគល់ឱ្យ។

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យត្រូវដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣៣ .- ថ្មី**

នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម មានភារកិច្ចដូចតទៅ៖

- កសាងផែនការយុទ្ធសាស្ត្រនិងផែនការគម្រោងកម្មវិធី ដើម្បីគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាពដោយឈរលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ធនធានដីកសិកម្មប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបណ្តាអនុសញ្ញា កិច្ចព្រមព្រៀងក្របខ័ណ្ឌថ្នាក់ជាតិ តំបន់ និងអន្តរជាតិ
- កំណត់ទិសដៅយុទ្ធសាស្ត្រ ជំរុញសកម្មភាពពិសោធន៍ស្រាវជ្រាវ និងការផ្ទេរបច្ចេកវិទ្យាស្តីពីការគ្រប់គ្រងដីកសិកម្ម ការទប់ស្កាត់ការធ្លាក់ចុះគុណភាពដី កសិកម្មអភិរក្សនិងកសិអេកូឡូស៊ី

ការអភិរក្សដីនិងទឹកកសិកម្ម ការប្រើប្រាស់ដីកសិកម្ម និងប្រព័ន្ធកសិកម្មវៃឆ្លាតនឹងអាកាសធាតុ ដោយឈរលើក្របខ័ណ្ឌនៃភាពជាដៃគូរវាងរដ្ឋ វិស័យឯកជន ដៃគូអភិវឌ្ឍនិងសហគមន៍កសិកម្ម

- សិក្សានិងអភិវឌ្ឍគោលការណ៍ណែនាំបច្ចេកទេស ដើម្បីគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព មានជាអាទិ៍ ការកំណត់តំបន់ដាំដុះ សារពើភ័ណ្ឌដីកសិកម្ម ការណែនាំក្នុងការប្រើប្រាស់ដី និងការកែលម្អដីជាតិដី
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីអភិរក្សដីកសិកម្មតាមរយៈការអនុវត្តកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពឱ្យស្របនឹងបរិបទនៃទំនើបកម្មកសិកម្ម
- ប្រើប្រាស់បច្ចេកវិទ្យាផ្កាយរណបនិងបច្ចេកវិទ្យាឌីជីថល ក្នុងការគ្រប់គ្រងធនធានដីកសិកម្ម ការប្រើប្រាស់ដីកសិកម្មនិងផលិតកម្មដំណាំ ការតាមដាននិងការវាយតម្លៃឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើផលិតកម្មដំណាំ និងការផលិតព័ត៌មានកសិឧតុនិយម
- ជាសេនាធិការបច្ចេកទេសក្នុងការតាមដាន វាយតម្លៃ និងផ្តល់សេវាលើការគ្រប់គ្រងដីធ្លីកសិកម្ម ការវាយតម្លៃគុណភាពដី ការប្រើប្រាស់ដីកសិកម្ម កំណត់ប្រព័ន្ធរក្សេគ្របរិស្ថាននិងសេដ្ឋកិច្ចសង្គម និងតម្រូវការសារធាតុចិញ្ចឹមដំណាំ
- គ្រប់គ្រងនិងធ្វើអធិការកិច្ចលើសកម្មភាពពាក់ព័ន្ធនឹងដីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្មនិងការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិនិងសហការអនុវត្តគម្រោងស្រាវជ្រាវនិងអនុសញ្ញាកិច្ចព្រមព្រៀងដែលពាក់ព័ន្ធនានាក្នុងក្របខ័ណ្ឌថ្នាក់ជាតិ តំបន់ និងអន្តរជាតិ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលអគ្គនាយកប្រគល់ឱ្យ។

នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម ត្រូវដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រាបី .-**

មាត្រា២៦ថ្មី នៃអនុក្រឹត្យលេខ៨១ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ ត្រូវបានកែសម្រួលដូចខាងក្រោម៖

**មាត្រា២៦ .- ថ្មី(មួយ)**

អគ្គនាយកដ្ឋានកសិកម្ម មានភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើការងារដូចតទៅ៖

- លើកសំណើគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ កម្មវិធី គម្រោង និងវិធានការអភិវឌ្ឍផលិតកម្មដំណាំប្រកបដោយនិរន្តរភាព ផលិតភាព និងភាពប្រកួតប្រជែង
- ពិសោធ ស្រាវជ្រាវ អភិវឌ្ឍបច្ចេកវិទ្យា និងសិក្សាស្រាវជ្រាវសេដ្ឋកិច្ចសង្គមទាក់ទងនឹងកិច្ចអភិវឌ្ឍពិពិធភាវូបនីយកម្ម បង្កើនផលិតភាព និងកសិពាណិជ្ជូបនីយកម្មផលិតកម្មដំណាំ ដើម្បីចូលរួមធានាសន្តិសុខស្បៀង លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងជំរុញបង្កើនការនាំចេញកសិផល
- ជំរុញលើកកម្ពស់ការយល់ដឹងអំពីបច្ចេកទេសកសិកម្មដល់ប្រជាកសិករនិងអ្នកពាក់ព័ន្ធ ឱ្យបានទូលំទូលាយ ប្រកបដោយប្រសិទ្ធភាព តាមរយៈសកម្មភាពអប់រំ បណ្តុះបណ្តាល និងផ្ទេរបច្ចេកវិទ្យាគ្រប់រូបភាព

- ជំរុញការរៀបចំនិងគាំទ្រការប្រព្រឹត្តទៅ ការប្រតិបត្តិនិងការអភិវឌ្ឍរបស់សហគមន៍កសិកម្ម អង្គការផលិតករកសិកម្ម និងសម្របសម្រួលរវាងប្រតិបត្តិករសាធារណៈ ឯកជន និងផលិតករកសិកម្ម ដើម្បីបង្កើនសមត្ថភាព ស្ថាប័ន និងជំនាញបច្ចេកទេសកសិកម្មឱ្យក្លាយទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មជនបទ និងបង្កើនអំណាចចរចាទីផ្សារ
- ជំរុញបង្កើនផលិតភាពកសិកម្មនិងប្រាក់ចំណូលពីផលិតកម្មកសិកម្ម ដោយប្រើប្រាស់ពូជដំណាំ ជីកសិកម្ម ប្រព័ន្ធស្រោចស្រព វិធីសាស្ត្រដាំដុះ វិធានការអនាម័យនិងភូតគាមអនាម័យ ការពារដំណាំ និងគ្រឿងយន្តកសិកម្មសមស្របតាមក្សេត្របរិស្ថាន និងលក្ខខណ្ឌភូមិសាស្ត្រសេដ្ឋកិច្ចសង្គម
- ផ្តល់សេវាវិភាគស្រាវជ្រាវ វាយតម្លៃគុណភាព និងសុវត្ថិភាព ដី ជី ទឹក រុក្ខជាតិ ថ្នាំកសិកម្ម ស្ថានភាពសុខភាពដំណាំ ពូជគ្រប់ប្រភេទនៃដំណាំ កំណត់អត្តសញ្ញាណកម្មសមាសភាពចង្រៃ ភ្នាក់ងារជីវសាស្ត្រដែលប្រើប្រាស់ក្នុងផលិតកម្មដំណាំ និងសំណល់សារធាតុគីមីនិងសំណល់ជីវសាស្ត្រកសិកម្ម ដើម្បីគាំទ្រក្នុងផលិតកម្ម និងកសិពាណិជ្ជូបនីយកម្មកសិកម្ម
- រៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នានាដែលពាក់ព័ន្ធ ដើម្បីបម្រើឱ្យការអភិវឌ្ឍអនុវិស័យដំណាំ
- ជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង ការអនុវត្តវិធានការការពាររុក្ខជាតិ អនាម័យ និងភូតគាមអនាម័យប្រកបដោយប្រសិទ្ធភាពនិងភាគបរិស្ថាន ដើម្បីលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពស្បៀងមានដើមកំណើតពីរុក្ខជាតិ
- តាមដាន ព្យាករសក្តានុពលហានិភ័យ និងចាត់វិធានការអន្តរាគមន៍សង្គ្រោះនិងស្តារការខូចខាតដំណាំដែលបង្កដោយគ្រោះធម្មជាតិនិងការរាតត្បាតពីសំណាក់សមាសភាពចង្រៃផ្សេងៗ
- ជំរុញកិច្ចសហការនិងអនុវត្តស្តង់ដា គោលការណ៍ណែនាំ ពិធីសារ អនុស្សរណៈ កិច្ចព្រមព្រៀង និងបណ្តាលិខិតបទដ្ឋានកម្រិតជាតិ តំបន់ និងអន្តរជាតិ
- តាមដាន វាយតម្លៃគុណភាពដី ការប្រើប្រាស់ដី កំណត់ប្រព័ន្ធក្សេត្របរិស្ថាន និងសេដ្ឋកិច្ចសង្គម ដើម្បីកំណត់តំបន់ដាំដុះកសិកម្មប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច
- គ្រប់គ្រងនិងធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីធានាការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ចូលរួមលើកកម្ពស់ផលិតភាពកសិកម្ម សុខភាពសាធារណៈ និងនិរន្តរភាពនៃបរិស្ថាន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

អគ្គនាយកដ្ឋានកសិកម្ម ដឹកនាំដោយអគ្គនាយកមួយរូបនិងមានអគ្គនាយករងមួយចំនួនជាជំនួយការដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៥ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនៃអគ្គនាយកដ្ឋាននិងនាយកដ្ឋានពាក់ព័ន្ធខាងលើ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា១៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាប្រាំមួយ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាប្រាំមួយ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ